**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខ:..........................

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប្រាវីត វង្សសុវណ្ណ** (Prawit Wongsuwon ) ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រថៃ ។ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយគណៈប្រតិភូជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ នឹងអញ្ជើញទៅចូលរួម **កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ លើកទី១៣** ( **The 13th General Border Committee Meeting "GBC"** ) នៅថ្ងៃទី២០-២១ ខែមីនា ឆ្នាំ២០១៨ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ។

គោលបំណងនៃកិច្ចប្រជុំខាងលើ ផ្តោតយ៉ាងសំខាន់លើការពង្រឹងទំនាក់ទំនង និងលើកកំពស់កិច្ចសហប្រតិបត្តិការរវាងកងទ័ពនៃប្រទេសទាំងពីរ **កម្ពុជា-ថៃ** ជាពិសេសដើម្បីរឹតចំណងមិត្តភាព និង ពង្រីកដែនកិច្ចសហប្រតិបត្តិការដូចជា: ផ្នែកសន្តិសុខ ការអភិវឌ្ឍន៍ និង ដើម្បីទប់ស្កាត់បង្ក្រាបនូវរាល់អំពើអសកម្ម និង អំពើខុសច្បាប់នានា រួមទាំងស្វែងរកដំណោះស្រាយ និង វិធានការរួមគ្នា ដើម្បីរក្សា និង ធានាអោយបាននូវទំនាក់ទំនងល្អក្នុងការជម្រុញអោយមាននូវសន្តិភាព ស្ថេរភាព សន្តិសុខ និងការអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរ **កម្ពុជា-ថៃ**៕

ថ្ងៃពុធ ១៤រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៨